**ប្រការ ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ប្រតិភូរាជរដ្ឋាភិបាល អភិបាលខេត្ត-ក្រុង និងឯកឧត្តម **ឌឹម ឈុនលីម** ត្រូវអនុវត្ត សេចក្តីសំរេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

***

រាជធានីភ្នំពេញ,ថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ២០០១

**សេចក្តីសំរេច លេខ ២៥ សសរ**

**ស្តីពី**

**ការផ្ទេរសិទ្ធិ**

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែល ប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

**សំរេច**

**ប្រការ ១ :** ត្រូវបានផ្ទេរសិទ្ធិជូនឯកឧត្តម **ស៊ុយ សែម** រដ្ឋមន្ត្រីក្រសួង ឧស្សាហកម្ម រ៉ែ និងថាមពល ជារដ្ឋមន្ត្រីស្តីទី ក្រសួងពាណិជ្ជកម្ម ជំនួសឯកឧត្តម **ចម ប្រសិទ្ធ** ដែលត្រូវអញ្ជើញទៅបំពេញ បេសកកម្ម នៅបរទេស ចាប់ពីថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០០១ រហូតដល់ឯកឧត្តម **ចម ប្រសិទ្ធ** វិលត្រឡប់មកវិញ ។

www.pheakdeylaw.com

**ប្រការ ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ប្រតិភូរាជរដ្ឋាភិបាល អភិបាលខេត្ត-ក្រុង និងឯកឧត្តម **ស៊ុយ សែម** ត្រូវអនុវត្តសេចក្តីសំរេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

***

រាជធានីភ្នំពេញ,ថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ២០០១

**សេចក្តីសំរេច លេខ ២៦ សសរ**

**ស្តីពី**

**ការប្រគេនលិខិតឆ្លងដែន និងសំបុត្រយន្តហោះ ចំពោះគណៈប្រតិភូ ព្រះសង្ឃ និងសមណសិស្ស និស្សិត ដែលត្រូវនិមន្តទៅបរទេស**

៚

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

**សំរេច**

**ប្រការ ១ :** ត្រូវបានប្រគេនលិខិតឆ្លងដែនដោយឥតគិតថ្លៃ ចំពោះគណៈប្រតិភូព្រះសង្ឃ និងសមណសិស្ស និស្សិត ដែលត្រូវនិមន្តទៅបំពេញទស្សនកិច្ចជាផ្លូវការ ឬនិមន្តទៅបំពេញការសិក្សានៅឯបរទេស ។

**ប្រការ ២ :** ចំពោះសំបុត្រយន្តហោះ ត្រូវពិនិត្យទៅលើស្ថានភាពជាក់ស្តែង នៃប្រទេសនីមួយៗ ក្នុងករណីដែលសាមីប្រទេសបាននិមន្ត ឬផ្តល់អាហារូបករណ៍ពុំមានលទ្ធភាព រាជរដ្ឋាភិបាលត្រូវទទួលបន្ទុកដោះស្រាយប្រគេន ។

www.pheakdeylaw.com